# ការបង្ការ និងការទប់ស្កាត់ជម្ងឺផ្តាសាយបក្សី ក្នុងការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារ




## សៀវភៅណែនាំសម្រាប់ ភ្នាក់ងារសុខភាពសត្វភូមិ និងមេភូមិ

**បោះពុម្ពដោយៈ**

នាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ដោយមានការគាំទ្របច្ចេកទេសពីៈ**

អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ

**អាសយដ្ឋានៈ**

ផ្លូវសទ្បា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ

ក្រុងភ្នំពេញ ប្រទេសកម្ពុជា

**ប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍សម្រាប់សុខភាពសត្វៈ**

០១២ ៨៣៣ ៧៩៥

០១២ ២១៤ ៩៧០

បោះពុម្ពលើកទី១ : ខែ មិថុនា ឆ្នាំ ២០០៨

បោះពុម្ពលើកទី២ : ខែ មេសា ឆ្នាំ ២០០៩

រូបថតនៅលើគំរបសៀវភៅៈ ភ្នាក់ងារសុខភាពសត្វភូមិ ជាមួយសំភារៈការពារខ្លួន និងសំភារៈផ្សព្វផ្សាយ

# សេចក្តីថ្លែងអំណរគុណ

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិប្រចាំប្រទេសកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងរដ្ឋាភិបាលអាល្លឺម៉ង់ដែលបានផ្តល់មូលនិធិសម្រាប់ការចងក្រង និងបោះពុម្ពសៀវភៅនេះឡើង។

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ប្រចាំប្រទេសកម្ពុជាសូមថ្លែងអំណរគុណផងដែរ ចំពោះអង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ និងបណ្ឌិតសភាសម្រាប់អភិវឌ្ឍន៍ការអប់រំដែលអនុញ្ញាតឱ្យនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រើប្រាស់នូវឯកសារមួយចំនួន សម្រាប់ជាឯកសារយោង។



AIDOC

Code: 231-013

Date:

Donated by:

# តារាងមាតិកា


I. សេចក្ដីផ្ដើម ............ ៥
II. អ្វីទៅជាជម្ងឺ "ផ្ដាសាយបក្សី"? ............ ៩
១. និយមន័យ ............ ៩
២. តើជម្ងឺនេះមានរោគសញ្ញាដូចម្ដេច? ............ ១២
ក. រោគសញ្ញាលើមាន់ ............ ១២
ខ. រោគសញ្ញាលើទា និងក្ងាន ............ ១៤
គ. រោគសញ្ញាលើមាន់បារាំង និងមាន់ពង ............ ១៤
៣. តើអ្នកអាចសំគាល់ភាពស្រដៀងគ្នារវាងជម្ងឺផ្ដាសាយបក្សី និងជម្ងឺដទៃទៀតដោយរបៀបណា? ............ ១៥
៤. តើជម្ងឺផ្ដាសាយបក្សីឆ្លងដោយរបៀបណា? ............ ១៧
ក. ការចម្លងជម្ងឺទៅកាន់បក្សី និងពីបក្សីមួយទៅបក្សីមួយទៀត ............ ១៧
ខ. ការចម្លងជម្ងឺពីបក្សីទៅមនុស្ស ............ ២០
III. តើអ្នកអាចបង្ការ និងទប់ស្កាត់ការរាលដាលជម្ងឺផ្ដាសាយបក្សីដោយរបៀបណា? *តើអ្នកត្រូវការជីវសុវត្ថិភាពក្នុងកម្រិតណា?* ............ ២១
១. ជីវសុវត្ថិភាព ............ ២១
២. អនាម័យផ្ទាល់ខ្លួន ............ ២៥
ក. បញ្ជីសំភារៈការពារខ្លួន ............ ២៥
ខ. របៀបពាក់សំភារៈការពារខ្លួន ............ ២៦
គ. របៀបដោះសំភារៈការពារខ្លួន ............ ២៨
៣. វិធានការណ៍ចត្តាឡីស័ក ............ ៣១
៤. ការអង្កេត និងការតាមដាន ............ ៣២
៥. ការរាយការណ៍ ............ ៣៣
៦. វិធានការណ៍ដទៃទៀតដើម្បីទប់ស្កាត់ជម្ងឺផ្ដាសាយបក្សី ............ ៣៦

**IV.** តើត្រូវអប់រំផ្សព្វផ្សាយអ្វីខ្លះនិងនៅពេលណា? ............................ ៣៨
១. នៅពេលដែលគ្មានផ្ទុះជម្ងឺ........................................................៣៨
ក. ចត្តាឡីស័ក ............................................................... ៣៩
ខ. បំបែកបក្សីទៅតាមប្រភេទផ្សេងពីគ្នា.......................................៣៩
គ. បោសសំអាត ............................................................... ៤០
ឃ. រាយការណ៍..................................................................៤២
ង. កប់ ឬ ដុតចោល..........................................................៤៣
ច. សារបន្ថែមសម្រាប់អ្នកទិញលក់បក្សី......................................៤៣
២. នៅពេលដែលមានផ្ទុះជម្ងឺនៅក្នុងភូមិដែលនៅក្បែរខាង.......................... ៤៥
ក. សារសម្រាប់កសិករ............................................................ ៤៥
ខ. សារបន្ថែមសម្រាប់អ្នកលក់ដូរបក្សី........................................... ៤៦
៣. នៅពេលដែលមានផ្ទុះជម្ងឺនៅក្នុងភូមិរបស់អ្នក........................................៤៧
ក. សារសម្រាប់កសិករ និងសាធារណជនទូទៅ.................................... ៤៩
ខ. សារសម្រាប់អ្នកលក់ដូរបក្សី..................................................... ៥០
៤. ការអប់រំផ្សព្វផ្សាយបន្ទាប់ពីមានការផ្ទុះជម្ងឺនៅក្នុងភូមិរបស់អ្នក....... ៥១

## ចំណងជើងរឿង

១. ការចម្លងជម្ងឺផ្តាសាយបក្សីពីបក្សីទៅបក្សី.............................. ៥២
២. ការចម្លងជម្ងឺផ្តាសាយបក្សីពីបក្សីទៅមនុស្ស.......................... ៥៦

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១: ទម្រង់របាយការណ៍ពីករណីបក្សីងាប់.......................... ៦០
ឧបសម្ព័ន្ធទី ២: តើមានសារសំខាន់ៗអ្វីខ្លះ និងមូលហេតុរបស់សារទាំងនោះ
មានអ្វីខ្លះ?.......................................................... ៦១

# I. សេចក្តីផ្តើម



មាន់ និងបក្សីដទៃទៀត គឺជាប្រភពប្រូតេអ៊ីនដ៏សំខាន់ សម្រាប់ទ្រទ្រង់សារពាង្គកាយមនុស្សនិងសត្វ។ ជាទូទៅប្រជាពលរដ្ឋចិញ្ចឹមបក្សីគឺសំខាន់សម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារក្រៅពីនោះពួកគាត់អាចយកទៅលក់ដើម្បីបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារទៀតផង។

ជម្ងឺផ្តាសាយបក្សី បង្កឱ្យមានការគំរាមកំហែងមួយដល់គ្រប់ការចិញ្ចឹមបក្សីទាំងអស់ ហើយអាច បង្កមហន្តរាយដល់កសិដ្ឋានទាំងមូល ឬ ដល់បក្សីទាំងហ្វូង ។ ប្រសិនបើមិនមានការប្រុងប្រយ័ត្នជាមុនឱ្យបានត្រឹមត្រូវនោះទេ ជម្ងឺនេះក៏អាចឆ្លងរាលដាលយ៉ាងងាយ ទៅកាន់កសិដ្ឋានដែលនៅជិតខាង ហើយបង្កឱ្យមានបញ្ហាដូចគ្នា ។ ប្រសិនបើមិនបានអនុវត្តត្រឹមត្រូវតាមនិតិវិធីនៅមុនពេល ក្នុងកំឡុងពេល និងក្រោយពេលផ្ទុះជម្ងឺ វីរុសនេះអាចរស់នៅក្នុងបរិស្ថានក្នុងរយៈពេលយូរ ហើយអាចចម្លងដល់ហ្វូងបក្សីជាបន្តបន្ទាប់ នៅក្នុងកសិដ្ឋានតែមួយនោះ ។ បន្ទាប់មក វដ្តនៃការចម្លងនេះនឹងបន្តមានថែមទៀត ។ ជម្ងឺផ្តាសាយបក្សី អាចរីករាលដាលនៅក្នុងតំបន់ និងប្រទេសទាំងមូលដែលមិនត្រឹមតែប៉ះពាល់ដល់សេដ្ឋកិច្ច តាមមូលដ្ឋានប៉ុណ្ណោះទេថែមទាំងដល់សេដ្ឋកិច្ចជាតិថែមទៀតផង ។ វាក៏អាចប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសដទៃទៀត មិនត្រឹមតែពាណិជ្ជកម្មបក្សីប៉ុណ្ណោះទេ គឺថែមទាំងប៉ះពាល់ដល់ពាណិជ្ជកម្មសត្វផ្សេងទៀតផងដែរ ។

នាពេលបច្ចុប្បន្ននេះជម្ងឺផ្តាសាយបក្សី ប្រភេទ HPAI/H5N1 កំពុងកើតមានឡើងនៅក្នុងបណ្តាប្រទេសជាច្រើននៅក្នុងពិភពលោក ជាពិសេស នៅអាស៊ី និងអឺរ៉ុប ។ ជម្ងឺនេះត្រូវបានគេរកឃើញក្នុងខ្លួនបក្សីចិញ្ចឹមបែបឧស្សាហកម្ម បក្សីចិញ្ចឹមជាលក្ខណៈគ្រួសារ បក្សីទឹក និងបក្សីពនេចរ ។ ជម្ងឺផ្តាសាយបក្សីគឺជា ជម្ងឺដែលអាចចម្លងមកមនុស្ស ហើយ មនុស្សអាចរងផលប៉ះពាល់ និងស្លាប់បាន ប្រសិនបើបានប៉ះពាល់ជាមួយនឹងវីរុសនេះ ។



ប្រជាជនកម្ពុជាខ្លះ រស់នៅកៀកនឹងហ្វូងបក្សី

រហូតមកដល់ថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ២០០៩ មានប្រទេសចំនួន ៦០ នៅក្នុងអាស៊ី អឺរ៉ុប និងអាហ្វ្រិក មានផ្ទុះជម្ងឺផ្តាសាយបក្សីដែលបង្ក

ដោយវីរុស H5N1 ហើយគេរកឃើញមនុស្សឆ្លងជម្ងឺនេះចំនួន៤១៣ករណីដែលពាក់ព័ន្ធជាមួយនឹងវីរុសប្រភេទ H5N1 ដែលក្នុងនោះមាន ២៥៦ ករណីបានស្លាប់ ។ ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ដែលមានជម្ងឺផ្តាសាយបក្សី ។ ករណីផ្ទុះជម្ងឺលើបក្សីដំបូងគេ ត្រូវបានគេរាយការណ៍ថា កើតឡើងនៅក្នុងខែ មករាឆ្នាំ ២០០៤ ហើយមានករណីផ្ទុះជម្ងឺផ្តាសាយបក្សីលើបក្សីចំនួន ២៣ ករណីផ្សេងទៀតបានកើតមានឡើងចាប់តាំងពីពេលនោះមកជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំដែលករណីចុងក្រោយកើតឡើងក្នុងខែធ្នូ ឆ្នាំ២០០៨ ក្នុងនោះមានករណីឆ្លងជម្ងឺដល់មនុស្សចំនួន ៨ បានកើតមានឡើង ហើយ៧ករណីបានស្លាប់ និង ១ករណីចុងក្រោយបានព្យាបាលទាន់ពេលវេលា និងជាសះស្បើយ ។


ភ្នាក់ងារសុខភាពសត្វភូមិក្នុងកំឡុងពេលចូលរួមវគ្គបណ្តុះបណ្តាល

បក្សីប្រហែលជា ១៦ លានក្បាល នៅក្នុងប្រទេសកម្ពុជា ត្រូវបានគេចិញ្ចឹមព្រលែងនៅតាមភូមិ ជាលក្ខណៈគ្រួសារ គឺមានមួយចំនួនតូចប៉ុណ្ណោះដែលចិញ្ចឹមជាលក្ខណៈពាក់កណ្តាលឧស្សាហកម្មនៅតាមកសិដ្ឋាន ។ ការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារ ពុំសូវមានជីវសុវត្ថិភាពនោះទេ ដូច្នេះហើយវិធានការណ៍ការពារជម្ងឺ និងការទប់ស្កាត់ក៏មិនសូវមាន ។ លើសពីនេះ ដោយសារតែមូលហេតុ "បារម្ភខ្លាចគេលួច" ជារឿយៗ បក្សីត្រូវបានគេដាក់នៅក្រោមផ្ទះនៅពេលយប់ ឬធ្វើទ្រុងដាក់នៅក្បែរនឹងផ្ទះ ហើយស្ថានភាពបែបនេះ ក៏ដូចគ្នានឹងបណ្តាប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ដែរ ។

ដោយសារតែកង្វះខាតជីវសុវត្ថិភាព និងការដែលមនុស្សប៉ះពាល់យ៉ាងជិតស្និទ្ធជាមួយនឹងបក្សីរបស់ពួកគេ ធ្វើឱ្យមានការភ័យខ្លាចពិតប្រាកដមួយថា ប្រភេទវីរុសបច្ចុប្បន្ននេះ (ដែលកំពុងបង្កវិនាសកម្ម ដល់បក្សីជាច្រើនក្បាល និងមនុស្ស

មួយចំនួន បានឆ្លងជម្ងឺនេះស្លាប់រួចទៅហើយ) អាចបន្តផ្លាស់ប្តូរទំរង់និង អាចក្លាយជាមូលហេតុនៃការរាតត្បាតជាសកលដល់មនុស្ស (ជម្ងឺដែលមានសក្តានុពលធ្វើឱ្យមនុស្សជាច្រើននាក់ទូទាំងពិភពលោកបាត់បង់ជីវិត) ។ គ្រប់ការប្រុងប្រយ័ត្នដែលចាំបាច់ទាំងអស់ មិនថាតូចតាចប៉ុណ្ណានោះទេ ត្រូវតែធ្វើឡើងដើម្បីបង្ការការរាតត្បាតជាសកលលើមនុស្សកើតមានឡើង ដោយសារតែបញ្ហាជម្ងឺផ្តាសាយបក្សីនេះ ។

ការណែនាំនេះផ្តោតលើវិធានការណ៍សម្រាប់បង្ការ និងទប់ស្កាត់ជម្ងឺផ្តាសាយបក្សី ។ ការណែនាំនេះត្រូវបានរៀបចំឡើង ជាការរំឭកដាស់តឿនយ៉ាងសាមញ្ញមួយអំពីចំណុចសំខាន់ៗ ដែលបានបណ្តុះបណ្តាលបន្ថែម ដល់ភ្នាក់ងារសុខភាពសត្វភូមិស្តីពីជម្ងឺផ្តាសាយបក្សីដូចជា:

- ការបង្ការជម្ងឺ
- ការសំគាល់ជម្ងឺ
- ការអង្កេតតាមដាន
- ការទប់ស្កាត់ជម្ងឺ
- ការរាយការណ៍ពីជម្ងឺ និងការអប់រំផ្សព្វផ្សាយដល់អ្នកភូមិ និងមន្ត្រីផលិតកម្ម និងបសុព្យាបាលស្រុក/ខេត្ត

# II. អ្វីទៅជាជម្ងឺផ្តាសាយបក្សី (Avian Influenza-AI ?)



វីរុសនៃជម្ងឺផ្តាសាយបក្សី

## ១. និយមន័យ

ជម្ងឺផ្តាសាយបក្សី គឺជាជម្ងឺម្យ៉ាងដែលបង្កឡើងដោយវីរុស ដូចគ្នានឹងជម្ងឺផ្តាសាយមនុស្សធម្មតាដែរ ។ ជម្ងឺនេះមានប្រភេទរបស់វាផ្សេងៗគ្នាជាច្រើន ដែលប្រភេទនីមួយៗខុសគ្នាតែបន្តិចបន្តួចតែប៉ុណ្ណោះ - ប្រភេទខ្លះស្រាល និងប្រភេទខ្លះទៀតធ្ងន់ធ្ងរ ។ ជម្ងឺផ្តាសាយបក្សីដែលមានកម្រិតចម្លងខ្ពស់ (Highly Pathogenic Avian Influenza - HPAI) គឺជាឈ្មោះដែលគេដាក់ឱ្យប្រភេទជម្ងឺផ្តាសាយបក្សី ដែលអាចបង្កឱ្យមានជម្ងឺធ្ងន់ធ្ងរ និងធ្វើឱ្យបក្សីស្រុកស្លាប់ក្នុងអត្រាខ្ពស់ ។

ជម្ងឺផ្តាសាយបក្សី គឺជាជម្ងឺដែលមានលក្ខណៈជាប្រព័ន្ធដែលអាចធ្វើឱ្យបាត់បង់ជីវិតក្នុងកម្រិតខ្ពស់ ។ ជម្ងឺនេះបង្កឡើងដោយវីរុស - ជាអតិសុខុមប្រាណដ៏សែនតូច ដែលមិនអាចមើលឃើញដោយភ្នែកទទេបាន ។ វាមិនមែនបង្កឡើងដោយព្រលឹងខ្មោចព្រាយបិសាច ឬដោយសារការផ្លាស់ប្តូរអាកាសធាតុនោះទេ ។

វីរុសផ្តាសាយបក្សី ត្រូវបានគេចែកចំណាត់ថ្នាក់ទៅតាមបណ្តុំប្រូតេអ៊ីន ចំនួនពីរក្រុមរបស់វាគឺ អេម៉ាគ្លុយទីនីន (Haemagglutinin) ឬ ប្រូតេអ៊ីន H និងណឺរ៉ាមីនីដាស (Neuraminidase) ឬ ប្រូតេអ៊ីន N។ ប្រភេទជម្ងឺផ្តាសាយបក្សីក៏ចែកចេញជាពីរក្រុម ផងដែរអាស្រ័យទៅតាម សមត្ថភាពរបស់វីរុស ក្នុងការបង្កជម្ងឺលើបក្សីៈ ជម្ងឺផ្តាសាយបក្សី ដែល មាន "កម្រិតចម្លងទាប" (Low Pathogenic Avian Influenza - LPAI) និង ជម្ងឺផ្តាសាយបក្សីដែលមាន "កម្រិតចម្លងខ្ពស់" (Highly Pathogenic Avian Influenza - HPAI)។ ជារឿយៗ ជម្ងឺផ្តាសាយបក្សី ធ្វើឱ្យបក្សីងាប់ ហើយ រាលដាលយ៉ាងលឿន។ HPAI/H5N1 គឺជាប្រភេទវីរុសដែលកំពុងរាលដាលយ៉ាង លឿននាពេលបច្ចុប្បន្ននេះនៅក្នុងប្រទេសមួយចំនួនក្នុងពិភពលោករួមទាំង ប្រទេសកម្ពុជាផងដែរ។



ជម្ងឺផ្តាសាយបក្សីបង្កឱ្យមានអត្រាស្លាប់ខ្ពស់លើហ្វូងមាន់

ជម្ងឺផ្តាសាយបក្សី គឺជាជម្ងឺដែលឆ្លងខ្លាំង ហើយអត្រាស្លាប់របស់វាអាចខ្ពស់ដល់ ១០០% ។ បក្សី គ្រប់ប្រភេទទាំងអស់ សុទ្ធតែងាយរងគ្រោះឆ្លងជម្ងឺផ្តាសាយបក្សី ប៉ុន្តែសំខាន់ជាងគេនោះ គឺការឆ្លងជម្ងឺនេះលើមាន់ មាន់បារាំង និងទា ដោយសារតែជម្ងឺនេះប៉ះពាល់ខ្លាំងដល់សេដ្ឋកិច្ចគួរឱ្យកត់សំគាល់ ។ វាក៏អាចឆ្លងដល់ក្ងាន ព្រាប ក្រួច ក្ងោក បក្សីទឹក បក្សីព្រៃ បក្សីសមុទ្រ ឬ បក្សីរស់នៅតាមឆ្នេរ និងបក្សីទឹកពនេចរដទៃទៀតផងដែរ ។

ជម្ងឺផ្តាសាយបក្សី បង្កឡើងដោយអតិសុខុមប្រាណម្យ៉ាងមានឈ្មោះថា វីរុស ដែលគេអាចមើលឃើញវាដោយប្រភេទមីក្រូទស្សន៍ពិសេសតែប៉ុណ្ណោះ ។ ជម្ងឺនេះមិនមែនបង្កឡើងដោយព្រលឹងខ្មោចព្រាយបីសាចធ្មប់ បណ្តាសា ឬដោយសារការផ្លាស់ប្តូរអាកាសធាតុនោះទេ ។

## ២. តើជម្ងឺនេះមានរោគសញ្ញាដូចម្ដេច?

ជម្ងឺផ្ដាសាយបក្សី អាចចម្លងដល់បក្សីមួយហ្វូងដោយធ្វើឱ្យមានអត្រាងាប់ខ្ពស់ជាញឹកញាប់វាកើតលើបក្សីដោយមិនចេញរោគសញ្ញាទាល់តែសោះ ប៉ុន្ដែងាប់ភ្លាមៗតែម្ដង។ រោគសញ្ញា និងការកើតជម្ងឺនេះអាចប្រែប្រួលអាស្រ័យទៅតាមៈ

- ប្រភេទវីរុសដែលចម្លងជម្ងឺ (LPAI ឬ HPAI)
- ប្រភេទបក្សីដែលឆ្លងជម្ងឺ
- អាយុរបស់បក្សី
- បរិស្ថាន និងជម្ងឺដទៃទៀតដែលប្រហែលជាមានក្នុងពេលជាមួយគ្នា

វីរុស អាចមាននៅក្នុងលាមក និងទឹកដែលជាកាកសំណល់ ដូចជា ទឹកមាត់ ទឹកភ្នែក និងទឹកសំបោរ។

### *ក. រោគសញ្ញាលើមាន់*

- អត្រាឈឺ និងអត្រាងាប់ខ្ពស់
- ពិបាកដកដង្ហើម ដកដង្ហើមក្រកៗ
- ខ្វិន ញ័រក្បាល រមួលក ( ជាពិសេស បក្សីដែលមានអាយុតិច)
- ដំណើរវិលវល់
- មិនស៊ីចំណី
- ចុះខ្សោយ និងក្បាលសំយ៉ុងចុះក្រោម
- សិរ និងណង់ហើមជាំឈាម ឡើងពណ៌ខៀវស្វាយ
- រាគរូសយ៉ាងខ្លាំង លាមកពណ៌បៃតង
- បះរោម
- ជាំឈាមនៅនឹងជើង និងផ្នែកផ្សេងទៀត ដែលគ្មានរោម
- ការផលិតស៊ុតមានការថយចុះ ហើយស៊ុតមានរូបរាងខុសប្រក្រតី ឯសំបកស៊ុតក៏ទន់។



ជាំឈាមនៅតាមជើង



ភ្នែកឡើងសល្អក់





រមួលក-តែវ៉ៃ

ជាំពណ៌ខៀវស្វាយ





មាន់ពិបាកដកដង្ហើម មាត់ចំហរ កត្រង់

### ខ. រោគសញ្ញាលើទា និងក្ងាន

- អង្គុយ ឬ ឈរ ក្នុងសភាពងងុយដេក ឬ អស់កម្លាំង
- ក្បាលសំយ៉ុងចុះប៉ះដី
- ភ្នែកឡើងស
- ហើមត្របកភ្នែក និងខ្ទង់ច្រមុះ
- រាគពណ៌ស ។



ភ្នែកសល្អក់

### គ. រោគសញ្ញាលើមាន់បារាំង និងមាន់ពង

- ហើមត្របកភ្នែក និងខ្ទង់ច្រមុះ
- រោគសញ្ញាផ្សេងទៀត ស្រដៀងគ្នានឹងមាន់យកសាច់ ។

## ៣. តើអ្នកអាចសំគាល់ភាពស្រដៀងគ្នារវាងជម្ងឺផ្តាសាយបក្សី និងជម្ងឺដទៃទៀតដោយរបៀបណា?

ជម្ងឺផ្តាសាយបក្សី គឺជាជម្ងឺមួយដែលមានលក្ខណៈជាប្រព័ន្ធមានន័យថា វីរុសនេះប៉ះពាល់ស្ទើរតែគ្រប់សរីរាង្គទាំងអស់របស់ខ្លួនប្រាណហើយក៏មានជម្ងឺដទៃទៀតបង្កឡើងដោយវីរុសនិងបាក់តេរីដែលមានលក្ខណៈជាប្រព័ន្ធផងដែរ ដូច្នេះជម្ងឺទាំងនោះបង្ហាញរោគសញ្ញាស្រដៀងគ្នានឹងជម្ងឺផ្តាសាយបក្សីដែរ ។

- ជម្ងឺញូវកាស (ដង្កោ) - គឺជាជម្ងឺមួយដែលបង្កឡើងដោយវីរុសនិងប៉ះពាល់ដល់ពពួកបក្សី ។ ជម្ងឺនេះស្រដៀងគ្នានឹងជម្ងឺផ្តាសាយបក្សីដែរហើយវាអាចឆ្លងដល់បក្សីទាំងតូចទាំងធំ ។ វាអាចប្រែប្រួលពីស្រាលទៅធ្ងន់ហើយទំរង់ធ្ងន់ធ្ងរនៃជម្ងឺនេះ បានបង្ហាញពីរោគសញ្ញាសរសៃប្រសាទ (រមួលក) គឺដូចគ្នានឹងជម្ងឺផ្តាសាយបក្សីដែរ ហើយក៏គ្មានថ្នាំសម្រាប់ព្យាបាលជម្ងឺនេះបានឡើយ ។
- ជម្ងឺប៉េស្តទា ជាជម្ងឺបង្កឡើងដោយវីរុស ដែលមិនឆ្លងមកមនុស្សឡើយ ។ ជម្ងឺនេះធ្វើឱ្យហូរឈាមនៅខាងក្នុង សត្វស្ថិតក្នុងសភាពរាគធ្ងន់ធ្ងរ និងប្រព័ន្ធបន្តពូជត្រូវបំផ្លាញ ។
- ជម្ងឺអាសន្នរោគបក្សី គឺជាជម្ងឺដែលបង្កឡើងដោយបាក់តេរីឈ្មោះថា ប៉ាស្ទើរ៉ែឡាម៉ាល់តូស៊ីដា (Pasteurella multocida) ។ ជម្ងឺនេះអាចព្យាបាលជាដោយប្រើថ្នាំអង់ទីប៊ីយ៉ូទិក ។
- ការពុល - កើតឡើងដោយសារតែប៉ះពាល់ ឬ ការស្រូបចូលសារធាតុគីមីមួយចំនួន ដូចជា ថ្នាំសម្លាប់សត្វចង្រៃ ថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់មេរោគ ឬ ការប្រើប្រាស់ថ្នាំមួយចំនួនលើសកម្រិតដោយចៃដន្យ ។ រោគសញ្ញាអាចស្រដៀងគ្នា នឹងជម្ងឺផ្សេងៗទៀតដូចជា ជម្ងឺផ្តាសាយបក្សីជាដើម ។

នៅពេលដែលសង្ស័យថាមានបក្សីកើតជម្ងឺផ្តាសាយបក្សីហ្វូងបក្សីវាជារឿងសំខាន់ណាស់ដែលអ្នកត្រូវតែទូរស័ព្ទទៅកាន់លេខទូរស័ព្ទទាន់ហេតុការណ៍របស់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលនៅនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល (NaVRI/DAHP) ។ បន្ទាប់ពីទូរស័ព្ទសាកសួររួច ប្រសិន

បើអ្នកផ្តល់ប្រឹក្សារបស់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលនៅមានការសង្ស័យថាអាចជាជម្ងឺផ្តាសាយបក្សីគាត់នឹងប្រាប់បញ្ហានេះទៅឱ្យមន្ត្រីផលិតកម្ម និងបសុព្យាបាលខេត្ត និងស្រុក ដើម្បីឱ្យពួកគេទៅកាន់កន្លែងកើតហេតុ និងធ្វើការស៊ើបអង្កេតឱ្យបានកាន់តែហ្មត់ចត់។ មន្ត្រីផលិតកម្ម និងបសុព្យាបាលខេត្ត/ស្រុក អាចយកសំណាកគំរូដែលចាំបាច់ (អាចជាបក្សីរស់ ឬ ងាប់ ឈាម ឬ សរីរាង្គ ផ្សេង ៗ)ហើយបញ្ជូនទៅកាន់មន្ទីរពិសោធន៍ ធ្វើរោគវិនិច្ឆ័យដើម្បីបញ្ជាក់ពីមូលហេតុនៃបញ្ហានេះ។ សូមចងចាំថា ដំណើរការនេះអាចចំណាយពេលជាច្រើនថ្ងៃ។ បន្ទាប់មកមន្ទីរពិសោធន៍នឹងអាចប្រាប់មកអ្នកវិញថា វាជា ជម្ងឺផ្តាសាយបក្សី មែន ឬ មិនមែន។



ការយកវត្ថុវិភាគពីបំពង់ខ្យល់មាន់

ជម្ងឺផ្តាសាយបក្សីអាចកើតមានឡើងភ្លាមតែម្តង រីករាលដាលបានលឿន និងមានអត្រាងាប់ខ្ពស់ ។ មាន់អាចមិនបង្ហាញរោគសញ្ញាលើកលែងតែឈឺយូរថ្ងៃមុនងាប់ ។ ទាអាចឆ្លងជម្ងឺនេះប៉ុន្តែមិនចេញរោគសញ្ញានៃជម្ងឺនេះឡើយ ។ គេពុំទាន់មានថ្នាំសម្រាប់ព្យាបាលជម្ងឺផ្តាសាយបក្សីនោះទេ ចាំបាច់ត្រូវតែធ្វើតេស្តក្នុងមន្ទីរពិសោធន៍ ដើម្បីបញ្ជាក់ពីជម្ងឺនេះ ។

## ៤. តើជម្ងឺផ្តាសាយបក្សីឆ្លងដោយរបៀបណា?

ការប៉ះពាល់ដោយផ្ទាល់រវាងបក្សីដែលមានសុខភាពល្អជាមួយនឹងបក្សីឈឺ គឺជាទំរង់ចម្លងជម្ងឺញឹកញាប់ជាងគេ ។

### ក. ការចម្លងជម្ងឺទៅកាន់បក្សី និងពីបក្សីមួយទៅបក្សីមួយទៀត

(១) តាមរយៈការប៉ះពាល់ដោយផ្ទាល់:



ទាដែលចិញ្ចឹមលែងដោយសេរី

- ទា ដែលចិញ្ចឹមឱ្យដើរដោយសេរី
- មាន់ ដែលចិញ្ចឹមជាលក្ខណៈគ្រួសារដើរពាសវាលពាសកាល
- បក្សីពនេចរ
- ទីផ្សារបក្សីរស់
- មាន់ជល់ ឬកន្លែងជល់មាន់



មាន់ដែលចិញ្ចឹមលែងតាមគ្រួសារ



បក្សីព្រៃ ពនេចរ



កន្លែងលក់សាច់បក្សី



កន្លែងលក់បក្សីរស់



កន្លែងប្រជល់មាន់

(២) ដោយប្រយោល - តាមរយៈការប៉ះពាល់ជាមួយនឹងសំភារៈដែលមានជាប់មេរោគ (លាមក សារធាតុរាវចេញពីខ្លួនសត្វ) ដែលជាប់មកជាមួយនឹងយានជំនិះ មនុស្ស សម្លៀកបំពាក់ ឧបករណ៍ និងបរិក្ខារនានា:

- សមាជិកគ្រួសារ ដែលវិលត្រឡប់ពីផ្ទះអ្នកជិតខាង ផ្សារ ស្រែ កន្លែងបក្សីទឹករកស៊ីចំណី

- បងប្អូនដែលមកលេងក្នុងឱកាសពិសេស
- ការមកលេងរបស់អ្នកជិតខាង



- ឈ្មួញកណ្ដាល ដែលមកទិញ ឬ លក់បក្សី ជ្រូក គោ និងផលិតផលកសិកម្មដទៃទៀត



- ភ្នាក់ងារសុខភាពសត្វភូមិ ដែលមកចាក់វ៉ាក់សាំងឱ្យសត្វ

- ការទិញចំណីសត្វ ឧបករណ៍ ។ល។ ដែលមានប្រភពមិនច្បាស់លាស់
- យានជំនិះដែលកខ្វក់ ចូលមកក្នុងកន្លែងចិញ្ចឹមសត្វនៅក្នុងភូមិ
- ឆ្កែ ឬ ឆ្មាដែលពាំសត្វងាប់
- ជីលាមកសត្វដែលទិញពីភូមិផ្សេងដែលស្គាល់ប្រភពមិនច្បាស់លាស់

## *ខ. ការចម្លងជម្ងឺពីបក្សីទៅមនុស្ស*

មនុស្សអាចឆ្លងជម្ងឺផ្តាសាយបក្សី នៅពេលប៉ះពាល់ដោយផ្ទាល់ជាមួយនឹងបក្សីដែលឆ្លងជម្ងឺ លាមកសត្វ និងសារធាតុរាវចេញពីខ្លួនរបស់បក្សីទាំងនោះ ។ វីរុសនេះក៏អាចចម្លងតាមរយៈការប៉ះពាល់ ជាមួយនឹងសំភារៈនានា ដែលមានជាប់មេរោគពីបក្សីមានជម្ងឺផងដែរ ។ដូច្នេះជាការសំខាន់ណាស់ដែលមនុស្សត្រូវអនុវត្តតាមវិធានជីវសុវត្ថិភាព និងធ្វើអនាម័យនិងរក្សាភាពស្អាតឱ្យបានហ្មត់ចត់ក្រោយពេលប៉ះពាល់បក្សី ផលិតផលបក្សី ឬសំភារៈប្រឡាក់មេរោគ ។ ចំណុចនេះនឹងយកមកពិភាក្សាលំអិតខាងក្រោមនេះ ។

នៅក្នុងប្រទេសកម្ពុជា គេបានរាយការណ៍ថា មានមនុស្សស្លាប់លើកដំបូងនៅក្នុងឆ្នាំ ២០០៥ ហើយករណីលើកទី ៨ បានកើតមាននៅក្នុងខែ ធ្នូឆ្នាំ ២០០៨ ។ គ្រប់ករណីទាំងអស់នេះ សុទ្ធតែមាន ទំនាក់ទំនងជាមួយនឹងការប៉ះពាល់បក្សីដោយផ្ទាល់ ។ រោគសញ្ញាមួយចំនួនលើមនុស្ស មានដូចជា ក្តៅខ្លួន ខ្លាំង ក្អក រាគ ក្អួត ឈឺពោះ ឈឺទ្រូង និងចេញឈាមតាមច្រមុះ និងអញ្ចាញ ។

> ជម្ងឺផ្តាសាយបក្សី ងាយឆ្លងពីបក្សីមួយទៅបក្សីមួយទៀត តាមរយៈការប៉ះពាល់ដោយផ្ទាល់ តាមលាមក ឈាម ទឹកមាត់ ទឹកសំបោរ ឬ ដោយប្រយោល នៅពេលដែលបក្សីស៊ីចំណី និងផឹកទឹកជាមួយគ្នា និងហែលក្នុងទឹកជាមួយគ្នា ។ វីរុសផ្តាសាយបក្សីក៏អាចចម្លងមកមនុស្សផងដែរ ។

## III. តើអ្នកអាចបង្ការ និងទប់ស្កាត់ការរាលដាលជម្ងឺផ្តាសាយបក្សីដោយរបៀបណា? តើអ្នកត្រូវការជីវសុវត្ថិភាពក្នុងកម្រិតណា?

### ១. ជីវសុវត្ថិភាព

ជីវសុវត្ថិភាព គឺជាពាក្យ ដែលគេប្រើជារួម ដើម្បីរៀបរាប់ពីវិធានការណ៍ផ្សេងៗ ធ្វើឡើងដោយ កសិករ អ្នកចិញ្ចឹមបក្សី (កសិដ្ឋានពាក់កណ្តាលឧស្សាហកម្ម និងកសិដ្ឋានឧស្សាហកម្ម) អ្នកលក់បក្សី និង ផលិតផលដើមកំណើតពីបក្សី និង អ្នកដឹកជញ្ជូន សំដៅបង្ការ និងបញ្ចៀសគ្រោះថ្នាក់នានា ដែលបង្កឡើងដោយជម្ងឺឆ្លង ។ វិធានជីវសុវត្ថិភាពទាំងនេះក៏ត្រូវបានអនុវត្តឡើងដើម្បីបង្ការ ជម្ងឺឆ្លងពីកន្លែងមួយទៅកន្លែងមួយទៀតផងដែរ ។

កម្មវិធីជីវសុវត្ថិភាព គួរត្រូវបានរៀបចំឡើងតាមរបៀបមួយ ដែលអាចឱ្យប្រជាជនធ្វើតាមបាន ។ កម្មវិធីនេះត្រូវតែមានលក្ខណៈល្អប្រសើរសម្រាប់ការអនុវត្តជាក់ស្តែង មិនមែនត្រឹមតែលើក្រដាសនោះទេ ។ កម្មវិធីនេះត្រូវអនុវត្តដោយមនុស្សគ្រប់រូប (គ្មានករណីលើកលែង) ជារៀងរាល់ថ្ងៃ ។ កម្មវិធីនេះត្រូវតែអាចយកមកអនុវត្តជាក់ស្តែងបាន និងរៀបចំដោយប្រើប្រាស់ការយល់ដឹងជាក់ស្តែងរបស់ប្រជាជន ។ លើសពីនេះទៅទៀតកម្មវិធីនេះគួរមានលក្ខណៈសន្សំសំចៃ ដើម្បីឱ្យប្រជាជនអាចមានលទ្ធភាពអនុវត្តន៍បាន ។

#### ជីវសុវត្ថិភាពជាមូលដ្ឋានក្នុងកសិដ្ឋាន:

ក. សង់ទ្រុងមាន់ ឱ្យនៅដោយឡែកពីកន្លែងរស់នៅរបស់គ្រួសារ និងឱ្យឆ្ងាយពីកន្លែងកខ្វក់

ខ. សង់របងនៅជុំវិញកន្លែងដែលមានបក្សី ដោយជ្រើសរើសសំភារៈណាដែលអាចរកបាននៅក្នុងភូមិ ដូចជាធាងត្នោត កូនឈើ ឬស្សី ឬ សំណាញ់ដែរ ។ល។ ដើម្បីធានាថា ឆ្កែ ឆ្មា និងបក្សីផ្សេង ទៀតមិនអាចចូលទៅក្នុងកន្លែងដែលមានបក្សីនេះបាន ។

គ.នៅពេលទិញបក្សីមកចិញ្ចឹម ត្រូវទិញពីប្រភពដែលអ្នកស្គាល់ដើម្បីឱ្យអ្នកដឹងច្បាស់ថាបក្សីទាំងនោះ ពិតជាមានសុខភាពល្អមែន

ឃ. ផ្តល់ចំណីស្អាត និងទឹកស្អាតឱ្យបក្សីរបស់អ្នក

ង. ដាក់បក្សីដែលទើបទិញមកថ្មី ឱ្យនៅដោយឡែកពីបក្សីចាស់ដែលមានស្រាប់នៅក្នុងកសិដ្ឋានឱ្យបានរយៈពេល ១៤ ថ្ងៃ ។ ប្រសិនបើបក្សីដែលទើបចូលថ្មីនេះមានជម្ងឺ នោះបក្សីចាស់ៗ នឹងមិនអាចឆ្លងពីវាបានឡើយ ។



ការបង្ខាំងមាន់ថ្មីទុករយៈពេល ១៤ថ្ងៃ

ច. កុំចិញ្ចឹមបក្សីប្រភេទផ្សេងគ្នាជាមួយគ្នា

ឆ. សំអាតផ្ទះ និងបរិវេណជុំវិញ ឱ្យបានទៀងទាត់ដោយបោសសំអាត និងចូកចោល

ជ. ដាក់បក្សីដែលឈឺ ឱ្យនៅដោយឡែកពីបក្សីដែលមានសុខភាពល្អ

ឈ. កុំទុកបក្សីងាប់ចោលនៅលើដី គឺត្រូវប្រមូលបក្សីទាំងនោះដោយប្រើស្រោមដៃស្បែកជើងកវែង និងថង់ប្លាស្ទិក ដោយដាក់បក្សីងាប់ទាំងនោះនៅក្នុងថង់ ហើយដាក់នៅក្នុងធុងបិទជិត ដែលនៅឆ្ងាយពីបក្សីផ្សេងទៀត កណ្តុរ ឬ សត្វ ដែលអាចហែកយកបក្សីងាប់ទាំងនោះ។ ធុងនោះត្រូវតែមានគម្របបិតជិត ដើម្បីកុំឱ្យរុយចូល ។ ម្ចាស់សត្វត្រូវកប់ធ្វើជាជីកំប៉ុស្ត ឬ ដុតបក្សីដែលងាប់ទាំងនោះឱ្យបានទៀងទាត់និងឱ្យឆ្ងាយពីកសិដ្ឋាន ហើយកុំចោលបក្សីងាប់ចូលទៅក្នុងស្រះ ត្រពាំង ទន្លេ ឬ ទុកវានៅតាមទីវាល និងកុំយកបក្សីងាប់ទាំងនោះមកបរិភោគ ឬ លក់ដូរឱ្យអ្នកដទៃ។



ការបាញ់ថ្នាំសម្លាប់មេរោគនៅបរិវេណទ្រុងមាន់

៣. ប្រើថ្នាំដើម្បីសម្លាប់មេរោគក្នុងទ្រុងមាន់ និងកន្លែងដែលនៅជុំវិញ។ សូមចងចាំថា ត្រូវយកកំទេច កំទីចេញសិន ទុកឱ្យស្ងួតស្អាតល្អ បន្ទាប់មកលាងសំអាត មុនពេលដែលអ្នកប្រើថ្នាំ សម្លាប់មេរោគ។ ថ្នាំសម្លាប់មេរោគ នឹងមិនមានប្រសិទ្ធភាពនៅកន្លែងដែលកខ្វក់ឡើយ។ ការសំអាត និងការសម្លាប់មេរោគត្រូវតែធ្វើបន្ទាប់ពីមានបក្សីឈឺ ឬងាប់ ឬ បន្ទាប់ពីពេលដែលបក្សី របស់អ្នកត្រូវបានអាជ្ញាធរសម្លាប់ចោល ដើម្បីបង្ការជម្ងឺនេះឆ្លងរាលដាលទៅកន្លែងផ្សេងទៀត។ វាគឺជាការអនុវត្តដ៏ល្អមួយផងដែរ នៅពេលដែលអ្នកសំអាត និងសម្លាប់មេរោគចោលបន្ទាប់ពីអ្នកបានលក់បក្សីទាំងអស់របស់អ្នកឬគ្រោងជំនួសបក្សីរបស់អ្នកជាមួយនឹងហ្វូងបក្សីថ្មី។ កុំភ្លេចលាងសំអាត និងសម្លាប់មេរោគគ្រប់ឧបករណ៍ និងសំភារៈទាំងអស់។

ង. កុំយកបក្សីដែលសល់ពីផ្សារចូលមកក្នុងកសិដ្ឋានវិញ ព្រោះបក្សីទាំងនោះអាចឆ្លងជម្ងឺពីបក្សីដទៃ ទៀតដែលប្រហែលជាឈឺ ។

ច. កុំលក់បក្សីដែលឈឺ ឬ យកបក្សីដែលឈឺទៅកាន់កន្លែងផ្សេងទៀត ។

ឆ. បំផ្លាញជម្រករបស់សត្វកណ្ដុរ សត្វល្អិត និងសត្វចង្រៃដទៃទៀតមិនឱ្យនៅក្នុងកសិដ្ឋាន ដោយធ្វើយ៉ាងណាកុំឱ្យមានសម្រាមនៅក្នុងកសិដ្ឋាន ។ ប្រមូលនិងដុតចោលសំរាមឱ្យបានទៀងទាត់ដើម្បីលុបបំបាត់ជំរកសត្វចង្រៃទាំងអស់នេះ ។

ឈ. ប្រឹក្សាជាមួយនឹងភ្នាក់ងារសុខភាពសត្វភូមិ និងមន្ត្រីផលិតកម្ម និងបសុពេទ្យាបាលខេត្ត ឬស្រុក ប្រសិនបើអ្នកសង្ស័យថា បក្សីរបស់អ្នកមានជម្ងឺ ។



ភ្នាក់ងារសុខភាពសត្វភូមិកំពុងត្រួតពិនិត្យមើលមាន់ឈឺ

កុំរង់ចាំទាល់តែដល់ធ្ងន់ធ្ងរ ។ កុំប្រើថ្នាំណាដែលភ្នាក់ងារសុខភាពសត្វភូមិ មិនបានណែនាំឱ្យប្រើ ព្រោះផលប៉ះពាល់មិនល្អអាចកើតមានឡើងធ្វើឱ្យបក្សីរបស់អ្នកកាន់តែឈឺ ។

## ២. អនាម័យផ្ទាល់ខ្លួន

២.១. លាងដៃឱ្យបានស្អាតជាមួយសាប៊ូ និងទឹក។




ផ្ទាំងរូបភាពផ្សព្វផ្សាយពីការលាងដៃជាមួយសាប៊ូ និងទឹក

២. ២. នៅពេលប៉ះពាល់ជាមួយបក្សីឈឺស្លៀកសម្លៀកបំពាក់និងស្បែកជើងការពារខ្លួន (សំភារៈការពារខ្លួន [PPE]) ។ ឧបករណ៍ទាំងនេះនឹងការពារអ្នកមិនឱ្យឆ្លងវីរុសផ្តាសាយបក្សីបាន ដោយសារតែគេមិនអាចមើលឃើញវានឹងភ្នែកទទេបានឡើយ ព្រោះវីរុសនេះមានទំហំតូចខ្លាំងណាស់។ សូមដោះសំភារៈការពារខ្លួននេះចេញ ហើយសំអាត និងសម្លាប់មេរោគជាមុនសិនមុនពេលអ្នកត្រឡប់ចូលមកក្នុងផ្ទះវិញ។

### ក. បញ្ជីសំភារៈការពារខ្លួន ដែលគួរមាន:

១. ខោអាវភ្លៀងមួយកំប្លេ (ខោ និងអាវដៃវែងមានគំរបក្បាល)

២.គំរបក្បាលដាច់ដោយឡែក (មានក៏បានអត់ក៏បានបើសិនបើអាវភ្លៀងពុំមានគំរបក្បាលរួច)

៣. វ៉ែនតាការពារ

៤. ម៉ាស់ អិន 95 (N95)

៥. ស្រោមដៃប្លាស្ទិក

៦. ស្បែកជើងកវែង

## ខ. របៀបស្លៀកពាក់ស



១. ស្លៀកខោ



២. ពាក់អាវ



៥. ត្រូវពាក់ឱ្យបានត្រឹមត្រូវ



៦. ច្របាច់ម៉ាស់ឱ្យជាប់នឹងក្តោងច្រមុះ



៩. ពាក់ស្រោមដៃដោយដាក់ដៃអាវ
គ្របពីលើ

# បំពាក់ការពារខ្លួន



៣. ពាក់ស្បែកជើងកវែង ដោយដាក់ជើងខោគ្របពីលើស្បែកជើង



៤. ពាក់ម៉ាស់



៧. ពាក់វ៉ែនតា



៨. ពាក់មួកហើយបិទឡេវឱ្យជាប់



១០. ស្លៀកពាក់រួចរាល់

# គ. របៀបដោះសម



១. លាងដៃនឹងទឹកសាប៊ូ ឬ ថ្នាំសម្លាប់មេរោគ



២. ដោះអាវហើយនិងមួក



៥. ដោះខោដោយមូរពីក្នុងមកក្រៅ



៦. ដោះស្បែកជើងកវែង



៩. ដោះម៉ាស់



# ពាក់ការពារខ្លួន



៣. ពន្លាត់អាវពីក្នុងមកក្រៅ



៤. រួចដាក់ក្នុងថង់យកទៅសម្លាប់មេរោគ



៧. ដាក់ស្បែកជើងនិងខោនៅក្នុង
ថង់តែមួយយកទៅសម្លាប់មេរោគ



៨. ដោះវ៉ែនតាដាក់ក្នុងថង់
យកទៅសម្លាប់មេរោគ



១០. ដាក់ម៉ាស់ក្នុងថង់យក
ទៅដុតចោល



១០. ដោះស្រោមដៃ

២.៣. ចៀសវាងប៉ះពាល់បក្សីដទៃទៀត ដូចជានៅពេលចូលរួមការប្រជល់មាន់ ការបរបាញ់បក្សី ការចូល រួមពិពណ៌ពាណិជ្ជកម្ម ឬ ការតាំងបង្ហាញបក្សី ។ល ។

២.៤. ក្មេងៗត្រូវលេង ឬ នៅឱ្យឆ្ងាយពីមាន់ ព្រោះមាន់ទាំងនេះអាចឈឺ ហើយអាចចម្លងវីរុសទៅឱ្យក្មេងៗ ។

២.៥. កុំបរិភោគបក្សីដែលឈឺ ឬងាប់ និងងឹក/បឹតឈាម

២.៦. ជានិច្ចជាកាល ត្រូវធ្វើតាមទំលាប់អនាម័យ នៅពេល សម្លាប់បក្សីដែលមានសុខភាពល្អដើម្បីយកមកបរិភោគ ។ សំអាតសាច់បក្សីដែលយកមកធ្វើម្ហូបឱ្យបានស្អាត ចោលគ្រឿងក្នុង និងរោម ដោយយកទៅដុត ឬ កប់ចោល សំអាតប្រដាប់ប្រដាផ្ទះបាយជាមួយនឹងសាប៊ូ និងទឹក ។

២.៧. ចំអិនបក្សីនិងស៊ុតឱ្យបានឆ្អិនល្អដោយដាក់សំភារៈប្រឡាក់ជាមួយសាច់




ផ្ទាំងរូបភាពផ្សព្វផ្សាយពីការចំអិនបក្សីដោយសុវត្ថិភាព

និងផលិតផលបក្សីឆៅ ឱ្យនៅដាច់ដោយឡែកពីសាច់ ឬផលិតផលបក្សីឆ្អិន
២.៨.កុំទទួលទាននៅជិតមាន់ ព្រោះរោម ធូលីនិងកំទិចកំទីតូចៗដែលមានជាប់លាមក អាចចូលទៅក្នុងអាហាររបស់អ្នក ។
២.៩.កុំហែល ឬ ងូតទឹកនៅក្នុងស្រះ ដែលធ្លាប់មានបក្សីហែល រកស៊ីចំណី ។

**សូមចងចាំ:**

ជម្ងឺផ្ដាសាយបក្សីអាចបង្ការបាន តាមរយៈវិធានការជីវសុវត្ថិភាព ។ វិធីសាស្ត្រទាំងនេះគួរមានលក្ខណៈសាមញ្ញ និងងាយស្រួលឱ្យកសិករ និងអ្នកដែលប៉ះពាល់បក្សីអាចអនុវត្តតាមបាន ។

ប្រសិនបើជម្ងឺផ្ដាសាយបក្សី ត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញនៅក្នុងកសិដ្ឋាន វិធានការណ៍ទប់ស្កាត់ដែលអនុវត្តប្រកបដោយប្រសិទ្ធភាព នឹងបង្ការជម្ងឺនេះឆ្លងទៅកាន់កសិដ្ឋាន ភូមិ និងខេត្តដទៃទៀតឡើយ ។

វិធានជីវសុវត្ថិភាពដែលល្អ នឹងមិនត្រឹមតែជួយមិនឱ្យមានជម្ងឺតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឱ្យបក្សីធំធាត់បានយ៉ាងល្អ ដើម្បីផលិតបានសាច់ និងស៊ុតបានច្រើនជាងមុន ។

## ៣. *វិធានការណ៍ចត្តាឡីស័ក*

នៅពេលដែលករណីផ្ទុះជម្ងឺកើតឡើង តំបន់ដែលមានជម្ងឺត្រូវបានកំណត់ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបង្ការមិនឱ្យជម្ងឺនេះឆ្លងរាលដាលទៅកាន់កសិដ្ឋានដែលនៅជិតខាង ។ នៅពេលដែលមានការកំណត់បែបនេះ ការចរាចរបក្សី សត្វផ្សេងទៀត និងសំភារៈនានា ទៅនិងមកពីតំបន់ដែលត្រូវបានបង្ខាំងដោយឡែក នឹងត្រូវបានហាមឃាត់ ។ តំបន់អាចបើកឱ្យប្រើប្រាស់តែនៅពេលដែលមានការសំអាត និងសម្លាប់មេរោគឱ្យបានត្រឹមត្រូវលើយានជំនិះ ហើយមានការអនុញ្ញាតពីអាជ្ញាធរតែប៉ុណ្ណោះ ។ នៅចំណុចនេះការប្រាស្រ័យទាក់ទងគ្នាបានត្រឹមត្រូវជាប្រចាំរវាងទីភ្នាក់ងារនិងអ្នកដែលមានការពាក់ព័ន្ធ គឺមានសារៈសំខាន់យ៉ាងខ្លាំង ។

## ៤. ការអង្កេត និងការតាមដាន



មន្ត្រីផលិតកម្ម និងបសុព្យាបាល កំពុងប្រមូលវត្ថុវិភាគពីបំពង់ខ្យល់មាន់នៅតាមផ្សារ

ការអង្កេត និងការតាមដាន អាចត្រូវបានគេប្រើជំនួសឱ្យគ្នាទៅវិញទៅមកបាន ប៉ុន្តែវិធីសាស្ត្រទាំងពីរនេះរួមមាន ការប្រមូល ការវិភាគ ការបកស្រាយ និងការចែកចាយទិន្នន័យជម្ងឺ ដែលមានលក្ខណៈជាប្រព័ន្ធ ដែលមានសារៈសំខាន់ចំពោះការធ្វើផែនការ ការអនុវត្ត និងការវាយ តំលៃការទប់ស្កាត់ និងការបង្ការជម្ងឺ ។ គោលដៅចំបងគឺត្រូវកាត់បន្ថយអត្រាឈឺ និងងាប់ និងធ្វើឱ្យបក្សីទទួលបានសក្តានុពល "ហ្សែន" ឱ្យបានពេញលេញ ។